# កិច្ចប្រជុំពេញអង្គចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ថ្ងៃទី១-៥ ខែកញ្ញា ឆ្នាំ២០០៨

## សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្តី

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨

១. អង្គភាពគាំពារការការពារក្តីសូមសម្តែងការអបអរសាទរចំពោះចៅក្រមទាំងអស់ ដែលបានអនុម័តវិសោធនកម្មសំខាន់ៗមួយចំនួនក្នុងកិច្ចប្រជុំពេញអង្គក្នុងសប្តាហ៍នេះ។ ចៅក្រមទាំងអស់បានប្រើនូវបញ្ញាញាណផ្នែកច្បាប់ដើម្បីដោះស្រាយបញ្ហាច្បាប់ដ៏ស្មុគស្មាញ ជាអាទិ៍មានតួនាទីនៃដើមបណ្តឹងរដ្ឋប្បវេណី និងការប្រើវិធានការការពារសាក្សីក្នុងការជំនុំជម្រះ។ ក្នុងន័យនេះ ចៅក្រមទាំងអស់បានបង្ហាញនូវការប្តេជ្ញាចិត្តពិតប្រាកដក្នុងការកែលំអដំណើរការប្រព្រឹត្តទៅនៃតុលាការ។

២. ប៉ុន្តែ អង្គភាពគាំពារការការពារក្តី មានការខកចិត្តដោយសារចៅក្រមបានអនុម័តវិសោធនកម្មវិធាន ១០៤ នៃវិធានផ្ទៃក្នុង ដែលកាត់បន្ថយវិសាលភាពនៃបណ្តឹងសាទុក្ខយ៉ាងច្រើន ដែលមានសម្រាប់ជនត្រូវចោទក្នុងករណីដែលតុលាការសម្រេចថាមានពិរុទ្ធភាព។ មុនពេលមានវិសោធនកម្មនេះ វិធានផ្ទៃក្នុងបានចែងស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលតាមបញ្ញត្តិនោះជនត្រូវចោទ ដែលត្រូវបានវិនិច្ឆ័យថាមានពិរុទ្ធភាពដោយអង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនោះ *ទាំងលើអង្គហេតុ និងអង្គច្បាប់។* វិសោធនកម្មលើវិធាន ១០៤ កម្រិតមូលដ្ឋានធ្វើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក.ត្រឹមតែ ១) កំហុសឆ្គងអង្គច្បាប់ដែលធ្វើឲ្យសេចក្តីសម្រេចគ្មានសុពលភាព ឬ ២) កំហុសឆ្គងអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចមិនមានភាពយុត្តិធម៌។ ចំណុចនេះមានន័យថាបច្ចុប្បន្ននេះ នៅអ.វ.ត.ក. ជនត្រូវចោទមានសិទ្ធិប្តឹងសាទុក្ខកាន់តែតិចជាងតុលាការផ្សេងទៀតនៅកម្ពុជា។

៣. ក្នុងកិច្ចប្រជុំពេញអង្គ អង្គភាពគាំពារការការពារក្តី បានស្នើឲ្យចៅក្រមបដិសេធសំណើវិសោធនកម្មវិធាន ១០៤។ គោលជំហររបស់យើងគឺថា តាមផ្លូវច្បាប់ចៅក្រមមិនមានអំណាចងាកចេញឆ្ងាយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាក្នុងកម្រិតមួយ ដែលអាចធ្វើការអនុម័តវិសោធនកម្មនេះបានទេ។ ទោះបីជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់អំណាចឲ្យចៅក្រមស្វែងរកវិធានទាំងឡាយសម្រាប់បំពេញបន្ថែមក្រមនីតិវិធីកម្ពុជាក៏ដោយ ការបំពេញបន្ថែមនេះអាចធ្វើបានតែក្នុងកាលៈទេសៈពិសេស និងក្នុងកម្រិតមួយជាក់លាក់តែប៉ុណ្ណោះ។ អង្គភាពគាំពារការការពារក្តីយល់ឃើញថា យើងពុំមានកាលៈទេសៈទាំងនោះជាមូលដ្ឋានដើម្បីស្នើសុំធ្វើវិសោធនកម្មនេះទេ។

៤. ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចៅក្រមយល់ឃើញថាវិសោធនកម្មនោះមានយុត្តិកម្មគ្រប់គ្រាន់ដោយយោងទៅលើលក្ខណៈពិសេសនៃអ.វ.ត.ក. ក៏ដូចជាការអនុវត្តន៍នៅក្នុងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិដទៃទៀត។

រីឆាត រ៉ចជឺរ (Richard Roger)
អនុប្រធាន និង ប្រធានស្តីទី
អង្គភាពគាំពារការការពារក្តី